អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ធនាគារពិភពលោកផ្តល់អនុសាសន៍សំខាន់ៗសម្រាប់ការស្តារសេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីវិបត្តិកូវីដ-១៩
- អាល្លឺម៉ង់ កំពុងសិក្សាលទ្ធភាពដើម្បីនាំចេញស្វាយកែវរមៀតកម្ពុជា ទៅទីផ្សារអាល្លឺម៉ង់ និងអឺរ៉ុប
- ADB អនុម័តផ្តល់ជំនួយ ៦,៨ លានដុល្លារ ដើម្បីជំរុញវិស័យទេសចរណ៍ និងផលិតកម្មស្រូវនៅកម្ពុជា
- កម្ពុជាកំពុងចរចាកិច្ចព្រមព្រៀងជៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេស៥បន្ថែមទៀត
- ដំណាំកាហ្វេ និងកាកាវនៅមណ្ឌលគិរីមានទីផ្សារល្អ ប៉ុន្តែការកែច្នៃ និងវិនិយោគនៅមានកម្រិត
- ពាណិជ្ជកម្មរបស់ប្រទេសម៉ាឡេស៊ី នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១
- អាមេរិកហាមការនាំចូលទំនិញពីក្រុមហ៊ុនម៉ាឡេស៊ី YTY Group ក្រោយសង្ស័យថា មានការរំលោភបំពានលើកម្មករ
- សន្ទស្សន៍ផលិតកម្មកម្មន្តសាល MPI ត្រៀមនឹងកើនឡើង ៤-៥%
- ចក្ខុវិស័យកំណើនសេដ្ឋកិច្ចវៀតណាម កាន់តែភ្លឺស្វាងនៅឆ្នាំ ២០២២
- លោកប្រធានាធីបតី ចូ បៃឌិន បានបញ្ចេញថវិកាជាង ១ប៊ីលានដុល្លារទៅតាមបណ្តារដ្ឋនានា ដើម្បីស្តារអណ្តូងប្រេង និងឧស្ម័នដែលត្រូវបោះបង់ចោលឡើងវិញ
- សហព័ន្ធការងារ និងសភានៃអង្គការឧស្សាហកម្មអាមេរិក (AFL-CIO)បានគាំទ្រយ៉ាងខ្លាំងចំពោះប្រព័ន្ធទូទាត់ អន្តរធនាគារ (CHIPs) ដែលជាកន្លែងទូទាត់ប្រាក់ចម្បងនៅUSA សម្រាប់ ប្រតិបត្តិការធនាគារធំរបស់ សភាអាមេរិកក្នុងការការប្រកួតប្រជែងក្នុងប្រទេសចិន


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី២ ខែកុម្ភៈ ឆ្នាំ២០២២ លេខ ៖ ១០៥

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ធនាគារពិភពលោកផ្តល់អនុសាសន៍សំខាន់ៗសម្រាប់ការស្តារសេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីវិបត្តិកូវីដ-១៩



*ប្រភព៖ Khmer Times ២០២២*

សេដ្ឋកិច្ចកម្ពុជា ស្ថិតក្នុងចំណោមសេដ្ឋកិច្ចនៃប្រទេសក្នុងតំបន់អាស៊ីបូព៌ា ដែលទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរពីការរាតត្បាតនៃជំងឺកូវីដ-១៩ នេះបើយោងតាមការលើកឡើងរបស់លោកស្រី Maryam Salim នាយកគ្រប់គ្រងនៃធនាគារពិភពលោកប្រចាំនៅកម្ពុជា ដោយផ្អែកតាមរបាយការណ៍ក្រោមចំណងជើងថា «ការអភិវឌ្ឍភាពធន់ដែលជាយុទ្ធសាស្ត្រសម្រាប់ធ្វើពិពិធកម្មគំរូលើកំណើនសេដ្ឋកិច្ចកម្ពុជា (Resilient Development, a Strategy to Diversify Cambodia's Growth Model)»។

កម្ពុជា ធ្លាប់សម្រេចបាននូវកំណើនសេដ្ឋកិច្ចយ៉ាងរឹងមាំក្នុងអត្រាជាមធ្យម ៧,៧% ចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៩ ប៉ុន្តែអត្រានេះបានធ្លាក់ចុះប្រមាណ ១០,១ ពិន្ទុភាគរយ មកនៅត្រឹម -៣,១% នៅឆ្នាំ២០២០ មុនពេលចាប់ផ្តើម កើនតិចតួចឡើងវិញក្នុងអត្រា ២,២% នៅឆ្នាំ២០២១។

ការធ្លាក់ចុះយ៉ាងគំហុកនៃសេដ្ឋកិច្ចនេះ ត្រូវបានសន្មតបណ្តាលមកពីការរាតត្បាតយ៉ាងខ្លាំងនៃជំងឺកូវីដ-១៩ ដោយឡែក ការពឹងផ្អែករបស់កម្ពុជាលើផលិតផល ទីផ្សារ និងប្រភពហិរញ្ញប្បទានដែលមានមូលដ្ឋានតូចចង្អៀត បានធ្វើឱ្យកម្ពុជាខ្វះជំហររឹងមាំក្នុងការទប់ទល់នឹងវិបត្តិដែលកើតមានចំពោះសេដ្ឋកិច្ច។ បន្ថែមពីនេះ ផលិតភាពពលកម្មរបស់កម្ពុជានៅមានកម្រិតទាប ដោយសារជំនាញនិងការបណ្តុះបណ្តាលនៅមានកម្រិតទាប ហើយ «កត្តាផលិតភាពសរុប» ដែលជារង្វាស់សម្រាប់កំណត់ប្រសិទ្ធផលដែលប្រទេសមួយប្រើប្រាស់កម្លាំងពលកម្ម និងដើមទុន ក៏នៅទាប ខណៈ អត្រាប្រាក់សន្សំនៅក្នុងប្រទេស ក៏មានកម្រិតទាប និងការវិនិយោគក្នុងស្រុកនៅមានកម្រិតទាបដែរនោះ បានធ្វើឱ្យកម្ពុជាត្រូវពឹងផ្អែកខ្លាំងទៅលើប្រភពហិរញ្ញប្បទាននៅក្រៅប្រទេស។

លោកស្រី Salim បានបញ្ជាក់ថា ដើម្បីកម្ពុជាអាចត្រលប់ទៅរកគន្លងកំណើនប្រកបដោយចីរភាពវិញ គឺតម្រូវឱ្យមានរបៀបវារៈកែទម្រង់ប្រកបដោយមហិច្ឆិតាមួយ ដែលផ្តោតលើការកែលម្អសមត្ថភាពរបស់ក្រុមហ៊ុនកម្មករ និងក្រុមគ្រួសារនៅកម្ពុជា ការធ្វើពិពិធកម្មនាំចេញ ការពង្រឹងបទប្បញ្ញត្តិដើម្បីដោះស្រាយការបំភ្លៃនៅលើទីផ្សារ ការកែលម្អបរិយាកាសធ្វើធុរកិច្ច និងការវិនិយោគបន្ថែមទៀតលើហេដ្ឋារចនាសម្ព័ន្ធ ដែលទ្រទ្រង់ដល់កំណើនប្រកបដោយគុណភាពខ្ពស់។

ជាមួយគ្នានេះដែរ «ចំណាត់ការគោលនយោបាយរយៈពេលខ្លី និងមធ្យមមួយចំនួន អាចគាំទ្រដល់យុទ្ធសាស្ត្រ

ស្តារសេដ្ឋកិច្ច ដែលនឹងអនុញ្ញាតឱ្យកម្ពុជាអាចកសាងសេដ្ឋកិច្ចបានរឹងមាំឡើងវិញបន្ទាប់ពីវិបត្តិកូវីដ-១៩»។ លោកស្រីបានបន្ថែមថា កម្ពុជាមានជម្រើសជាច្រើនក្នុងការដោះស្រាយបញ្ហាខ្វះពិពិធកម្មក្នុងសេដ្ឋកិច្ច និងការកសាងឡើងវិញឱ្យកាន់តែរឹងមាំ ដែលក្នុងនោះ មានដូចជា៖ ការវិនិយោគលើធនធានមនុស្ស ការធ្វើឱ្យការបែងចែកធនធានឱ្យកាន់តែមានប្រសិទ្ធភាពតាមរយៈការកែលម្អសមត្ថភាពស្ថាប័នទីផ្សារ និងបង្កើនការគ្រប់គ្រងការវិនិយោគសាធារណៈ។ បន្ថែមពីនេះ ការបង្កើនការរួមចំណែកទៅក្នុងខ្សែសង្វាក់តម្លៃសកល ការបង្កើតតម្លៃបន្ថែមក្នុងវិស័យកសិកម្ម និងការពង្រីកភាពប្រកួតប្រជែងក្នុងវិស័យសេវាកម្ម ក៏នឹងអាចជួយធ្វើឱ្យមានពិពិធកម្មលើការនាំចេញ ខណៈដែលការជំរុញការសន្សំប្រាក់ឱ្យមានកម្រិតកាន់តែខ្ពស់ ការលើកទឹកចិត្តដល់ការវិនិយោគបរទេសក្នុងវិស័យផលិតភាពខ្លាំងជាងគេ និងពង្រីកលទ្ធភាពក្នុងការស្វែងរកបានហិរញ្ញវត្ថុអាចគាំទ្រដល់ការវិនិយោគក្នុងស្រុក៕ *ដោយ ស៊ិន សុភារ៉*

*ប្រភព៖ [Khmer Times] ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២*

## អាល្លឺម៉ង់ កំពុងសិក្សាលទ្ធភាពដើម្បីនាំចេញស្វាយកែវរមៀតកម្ពុជា ទៅទីផ្សារអាល្លឺម៉ង់ និងអឺរ៉ុប



*ដោយ ខេមបូណ្ឌាមីស*

ក្រោយពីកម្ពុជា នាំចេញផ្លែស្វាយកែវរមៀតត្រង់ទៅកាន់ទីផ្សារចិន និងកូរ៉េខាងត្បូងរួចមក ពេលនេះផ្លែស្វាយកម្ពុជា នឹងមានទីផ្សារថ្មីមួយទៀត។ ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំកម្ពុជា បានបង្ហាញការចាប់អារម្មណ៍យ៉ាងខ្លាំងពីបច្ចេកទេសដាំដុះស្វាយកែវរមៀត និងមានបំណងនាំចេញ ទៅទីផ្សារអឺរ៉ុប ពិសេសទីផ្សារអាល្លឺម៉ង់តែម្តង។ ការបង្ហាញគោលបំណងនេះ បានធ្វើឡើងនាឱកាសទស្សនកិច្ចរបស់ឯកឧត្តមឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំកម្ពុជា និងក្រុមអ្នកជំនាញការអាល្លឺម៉ង់ នៅចម្ការស្វាយជម្ពូព្រឹក របស់ក្រុមហ៊ុន រីចហ្វាម។

ក្រុមហ៊ុន រីចហ្វាម បានសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម ក្នុងការអភិវឌ្ឍដំណាំឈើហូបផ្លែនៅកម្ពុជា ជាពិសេសការដាំដំណាំស្វាយ ឱ្យត្រូវនឹងស្តង់ដារដើម្បីនាំចេញ។ នេះគឺជាសញ្ញាវិជ្ជមានសម្រាប់អ្នកវិនិយោគក្នុងវិស័យកសិកម្ម ពិសេសកសិករដាំស្វាយ ដែលធ្លាប់ដាំដុះតាមបែបប្រពៃណីប្តូរមកដាំតាមលក្ខណៈបច្ចេកទេសវិញ ហើយអាចដោះស្រាយបញ្ហារបស់កសិករ ពិសេសបញ្ហាទីផ្សារ។ ដើម្បីដាំស្វាយ ឱ្យត្រូវនឹងស្តង់ដារខ្ពស់សម្រាប់នាំចេញ កសិករត្រូវរៀបចំប្រព័ន្ធស្រោចស្រពឱ្យបានត្រឹមត្រូវ ការមើលថែ ការកំណត់ពេលវេលាការវេចខ្ចប់ និងប្រមូលផល ជាដើម និងជាពិសេស ម្ចាស់ចម្ការស្វាយត្រូវចុះបញ្ជីចម្ការស្វាយជាមួយក្រសួងកសិកម្ម ដើម្បីអនុវត្តកសិកម្មល្អ(CamGAP)។

យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ នៅឆ្នាំ២០២១ កម្ពុជា បាននាំចេញផ្លែស្វាយស្រស់សរុប ជាង២៤ម៉ឺនតោន ទៅកាន់ទីផ្សារសំខាន់ៗ ដូចជា វៀតណាម ថៃ ចិន កូរ៉េខាងត្បូង ជាដើម។ ខណៈបច្ចុប្បន្ន កម្ពុជា មានផ្ទៃដីដាំដុះស្វាយសរុប ជាង ១០ម៉ឺនហិកតា និងទទួលបានទិន្នផលប្រមាណជិត២លានតោន ក្នុងមួយឆ្នាំ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌាមីសចេញផ្សាយថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២។*

# តើបច្ចេកវិទ្យាមានសារសំខាន់អ្វីខ្លះសម្រាប់អាជីវកម្ម ខ្នាតតូច និងមធ្យម?



*ដោយ ៖ ខេមបូណ្ឌមីស(សកម្មភាពវិចខ្ចប់នំស្រួយលីលី)*

នៅកម្ពុជា ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងវិស័យសហគ្រាសខ្នាតតូច និងមធ្យម(SME) មានការកើនឡើងគួរឱ្យកត់សម្គាល់ ពិសេសក្នុងបរិបទកូវីដ-១៩នេះតែម្តង។ បច្ចុប្បន្នមានអាជីវកម្ម SME ប្រមាណជា ២/៣ ហើយ កំពុងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងអាជីវ-កម្ម។ ស្របនឹងកំណើននេះ រាជរដ្ឋាភិបាលបានបង្កើតជាបទប្បញ្ញត្តិ និងយន្តការជាច្រើន សំដៅធានាការពារ និងលើកកម្ពស់និរន្តរភាពនៃសេដ្ឋកិច្ច និងសង្គមឌីជីថលនេះផងដែរ។

អ្នកនាំពាក្យក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេក-វិទ្យា និងនវានុវត្តន៍ បានកត់សម្គាល់ឃើញថា ត្បិតនៅអំឡុងវិបត្តិកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមានដល់អាជីវកម្ម SME ជាច្រើនរហូតមានអាជីវកម្មខ្លះក្ស័យធន ប៉ុន្តែ ការចាប់ផ្តើមអាជីវកម្មថ្មីៗ ជាពិសេសអាជីវកម្មទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក៏ចាប់ផ្តើមមានការកើនឡើង។ ទោះបី វិស័យ SME កាន់តែរីកចម្រើន តែផ្នែកធនធានមនុស្ស និងការប្រើប្រាស់បច្ចេកវិទ្យា ក្នុងវិស័យនេះ ហាក់នៅមានកម្រិតនៅឡើយ ដែលជាបញ្ហាប្រឈមត្រូវដោះស្រាយ។

ប្រធានសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម ក៏បានគូសបញ្ជាក់ដែរថា ការប្រាស់ប្រាស់បច្ចេកវិទ្យាឌីជីថល ពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងវិស័យ SME ក៏ប៉ុន្តែ បច្ចុប្បន្ន ការប្រើប្រាស់ឌីជីថលពីម្ចាស់អាជីវកម្ម ហាក់នៅមានកម្រិតនៅឡើយ។ ការជំរុញឱ្យម្ចាស់អាជីវកម្ម ងាកមកប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ហាក់មានភាពលំបាកបន្តិច ដូច្នេះ ត្រូវការពេលវេលាបន្ថែមដើម្បីអភិវឌ្ឍន៍វិស័យនេះ។ អាជីវកម្មភាគច្រើន ដែលទើបបង្កើតថ្មី គឺជាអាជីវកម្មទាក់ទងនឹងការកែច្នៃចំណីអាហារ ហើយភាគច្រើននៃអាជីវកម្មទាំងនោះ សុទ្ធតែបានប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងអាជីវកម្មរបស់ពួកគេ។

បច្ចុប្បន្ន នៅកម្ពុជាសហគ្រាសខ្នាតតូច និងមធ្យម មានប្រមាណជាង ៥៣ម៉ឺនសហគ្រាស កំពុងដំណើរការអាជីវកម្ម ហើយក្នុងនោះ មានតែប្រមាណជាង៤ម៉ឺនសហគ្រាសប៉ុណ្ណោះដែលបានចុះបញ្ជី។ បើយោងតាមធនាគារអភិវឌ្ឍន៍អាស៊ី(ADB) សហគ្រាសធុនតូចនិងមធ្យម នៅកម្ពុជា ត្រូវបានប៉ាន់ស្មានថា មានប្រមាណ ៩៩% នៃសហគ្រាសសរុប ដែលបានរួមចំណែកជិត ៦០% នៃផលិតផលក្នុងស្រុក និងបង្កើតការងារជាង ៧០% នៃកម្លាំងពលកម្ម។ ក៏ប៉ុន្តែ វិស័យ SME នៅកម្ពុជា បច្ចុប្បន្ន ហាក់នៅមានកម្រិត និងមានបញ្ហាប្រឈមជាច្រើន ដែលអាចជាឧបសគ្គក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព៕*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២។*

# កម្ពុជាកំពុងចរចាកិច្ចព្រមព្រៀងជៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេស៥បន្ថែមទៀត




*ដោយ ខេមបូណ្ណមីស*

កិច្ចព្រមព្រៀងជៀសវាងការយកពន្ធត្រួតគ្នា (DTA) គឺជាកិច្ចព្រមព្រៀងទ្វេភាគីដ៏សំខាន់បំផុត ក្នុងបរិបទនៃកិច្ចសហប្រតិបត្តិការផ្នែកពន្ធដារអន្តរជាតិ។

អ្នកជំនាញសេដ្ឋកិច្ចនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា បានគូសបញ្ជាក់ថា ការចុះកិច្ចព្រមព្រៀងជៀសវាងការយកពន្ធត្រួតគ្នា រវាងកម្ពុជា និងបណ្តាប្រទេសដទៃ ពិតជាចាំបាច់ណាស់ក្នុងទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគី។ កិច្ចព្រមព្រៀង នឹងជួយឱ្យទំនិញមានថ្លៃដើមទាប ហើយការចរាចរណ៍ទំនិញនៅលើទីផ្សារក៏មានតម្លៃសមរម្យដែរ។ សម្រាប់កម្ពុជា ដែលជាប្រទេសកំពុងមានតម្រូវការចាំបាច់ណាស់ ក្នុងការចុះកិច្ចព្រមព្រៀងជៀសវាងការយកពន្ធត្រួតគ្នា ជាមួយបណ្តាប្រទេសដទៃ ព្រោះវាក៏ជាផ្នែកមួយជួយជំរុញឱ្យវិនិយោគិនមកវិនិយោគនៅកម្ពុជា។

បើតាមរបាយការណ៍អគ្គនាយកដ្ឋានពន្ធដារ កម្ពុជា ចាប់ពីឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០២១ កម្ពុជា បានចុះកិច្ចព្រមព្រៀងជៀសវាងការយកពន្ធត្រួតគ្នា(DTA) ជាបន្តបន្ទាប់ជាមួយនឹងប្រទេសចំនួន១០ រួមមាន៖ សិង្ហបុរី ថៃ ចិន ប្រ៊ុយណេ វៀតណាម ហុងកុង ម៉ាកាវ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងប្រទេសកូរ៉េខាងត្បូង។

បច្ចុប្បន្ននេះ កម្ពុជាក៏បានកំពុងនឹងចរចាកិច្ចព្រមព្រៀងជៀសវាងការយកពន្ធត្រួតគ្នា ជាមួយប្រទេសជាច្រើនផ្សេងទៀតដែរ រួមមាន ប្រទេសហ្វីលីពីន ប្រទេសឡាវ ប្រទេសជប៉ុន ប្រទេសទួរគី និងប្រទេសអេមីរ៉ាតអារ៉ាប់រួមជាដើម។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ណមីសចេញផ្សាយថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២។*

# កាហ្វេ និងកាកាវនៅមណ្ឌលគិរីការកែច្នៃនៅមានកម្រិត



*ដោយ ខេមបូណ្ណមីស(គ្រាប់កាហ្វេ នៅមណ្ឌលគិរី)*

ខេត្តមណ្ឌលគិរី ជាខេត្តមួយដែលមានអំណោផលលើការដាំដុះដំណាំកសិកម្ម រួមទាំង ដំណាំឧស្សាហកម្ម ដូចជា កាហ្វេ និងកាកាវ ជាដើម។ សម្រាប់ដំណាំកាកាវ ជាដំណាំថ្មីមួយប្រភេទមានទីផ្សារ មិនចាញ់ដំណាំកាហ្វេនោះដែរ។

រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគូសបញ្ជាក់ថាដំណាំកាហ្វេ និងកាកាវ មិនសូវជាខុសគ្នាប៉ុន្មាននោះទេ ទាំងលើការដាំដុះ និងការថែទាំ គ្រាន់តែដំណាំប្រភេទនេះមិនត្រូវការកម្ដៅខ្លាំង និងទាមទារអាកាសធាតុត្រជាក់បន្តិចប៉ុណ្ណោះ។ ជាក់ស្តែង កសិករមួយចំនួន នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី បានជ្រើសរើសការដាំដុះដំណាំកាហ្វេ ជាមុខរបរបន្ទាប់បន្សំពីការធ្វើស្រែចម្ការ និងដាំបន្លែ ព្រោះតែដំណាំនេះមានតម្រូវការទីផ្សារខ្ពស់។ គ្រាប់កាហ្វេដែលស្ងួតមានតម្លៃ ៦០០០រៀល ក្នុងមួយគីឡូក្រាម។ ដំណាំទាំងពីរប្រភេទកំពុងមានតម្រូវការក្នុងស្រុកល្អ តែបើនិយាយពីបច្ចេកទេសកែច្នៃ និងការវិនិយោគ លើដំណាំនេះហាក់នៅ

មានកម្រិតនៅឡើយ។ ខេត្តមណ្ឌលគិរី ក៏មិនមែនជាកន្លែងដែលអំណោយផលខ្លាំងនោះដែរសម្រាប់ដំណាំកាហ្វេ ព្រោះដំណាំកាហ្វេ មានប្រភពពីតំបន់អាហ្វ្រិក និងត្រូវការលក្ខខណ្ឌច្រើន។ ដោយឡែក សម្រាប់ដំណាំកាកាវ ទោះជាប្រភេទដំណាំថ្មី តែបច្ចុប្បន្ន ក៏មានការដាំដុះនៅតាមបណ្តាខេត្តមួយចំនួនដែរ ដូចជា កំពង់ចាម បាត់ដំបង ប៉ៃលិន និងមណ្ឌលគិរី។

បណ្តុំកសិករដែលដាំដុះដំណាំកាហ្វេ បច្ចុបន្ននេះ មានប្រមាណ ៦០គ្រួសារ ស្ថិតនៅ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ ក្នុងមួយឆ្នាំកសិករអាចផលិតគ្រាប់កាហ្វេប្រមាណ៩០តោន ក្នុងមួយឆ្នាំសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២។*

## ADB អនុម័តផ្តល់ជំនួយ ៦,៨លានដុល្លារអាមេរិក ដើម្បីជំរុញវិស័យទេសចរណ៍ និងស្រូវអង្ករកម្ពុជា



The Asian Development Bank (ADB) has approved two grants to boost tourism and rice production in the Kingdom. ADB

*ប្រភព៖ Phnom Penh Post ២០២២*

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានយល់ព្រមផ្តល់ជំនួយសរុប ៦,៨លានដុល្លារអាមេរិក សម្រាប់គម្រោងចំនួន ២ ដើម្បីគាំទ្រដល់កម្ពុជាលើផ្លូវឆ្ពោះទៅរកការស្តារសេដ្ឋកិច្ច-សង្គមពីផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ ដែលគម្រោងទី១ នឹងជួយសហគមន៍ក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងសេវាកម្មអតិថិជនដើម្បីទាក់ទាញភ្ញៀវទេសចរកាន់តែច្រើន ក៏ដូចជាជំរុញសេដ្ឋកិច្ចក្នុងតំបន់។ ចំណែកឯ គម្រោងទី២ នឹងជួយកសិករដាំស្រូវនៅកម្ពុជា បង្កើនប្រាក់ចំណូល និងភាពធន់នឹងអាកាសធាតុ តាមរយៈការដោះស្រាយបញ្ហារំខានផ្នែកដឹកជញ្ជូន និងសង្វាក់ផ្គត់ផ្គង់ដែលបណ្តាលមកពីកូវីដ-១៩»។

សូមបញ្ជាក់ផងដែរថា គម្រោងទី១ មានទឹកប្រាក់ ៣,៧លានដុល្លារអាមេរិក ត្រូវបានរំពឹងថានឹងផ្តល់ប្រយោជន៍ដល់អ្នកភូមិចំនួន ៤ ០០០នាក់ តាមរយៈគម្រោងការស្តារសហគមន៍ទេសចរណ៍សម្រាប់ការងើបឡើងវិញពីជំងឺកូវីដ-១៩ ដែលគ្របដណ្តប់នៅតំបន់ក្បែរប្រាសាទព្រះវិហារ ក្នុងខេត្តព្រះវិហារ និងប្រាសាទភ្នំដា ក្នុងខេត្តតាកែវ។ ក្នុងនោះដែរ ទឹកប្រាក់ចំនួន ៣លានដុល្លារអាមេរិក នៃគម្រោងនេះ ត្រូវបានផ្តល់ដោយមូលនិធិជប៉ុនសម្រាប់វិបុលភាព និងភាពធន់នៅអាស៊ី និងប៉ាស៊ីហ្វិក។ គម្រោងទី២ មានទឹកប្រាក់ ៣,៩លានដុល្លារអាមេរិក នឹងផ្តល់ប្រយោជន៍ដល់កសិករខ្នាតតូចចំនួន ២២ ០០០នាក់ ដោយផ្តល់ហិរញ្ញប្បទានបន្ថែមសម្រាប់កម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មស្រូវ ដែលធន់នឹងអាកាសធាតុនៅក្នុងខេត្តបាត់ដំបង កំពង់ធំ និងព្រៃវែង។ ទឹកប្រាក់ចំនួន ៣,៨លានដុល្លារអាមេរិក នៃគម្រោងនេះ បានមកពីកម្មវិធីកសិកម្ម និងសន្តិសុខស្បៀងសកល ដែលជាមូលនិធិសកលក្នុងគោលបំណងកាត់បន្ថយភាពអត់ឃ្លាន និងកែលម្អអាហារូបត្ថម្ភនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប»។

ជាមួយគ្នានេះ ADB ប្តេជ្ញានឹងសម្រេចឱ្យបាននូវវិបុលភាព បរិយាប័ន្ន ភាពធន់ និងនិរន្តរភាពនៃអាស៊ី និងប៉ាស៊ីហ្វិក ស្របជាមួយការបន្តខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ភាពក្រីក្រខ្លាំង៕ *ដោយ ស៊ិន សុភាព៍*

*ប្រភព៖ Phnom Penh Post ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២*

## កូវីដ-១៩ អូមីក្រុង មិនរំខានដល់អាជីវករលក់គ្រឿងរណ្តាប់ និងគ្រឿងលម្អតុបតែងផ្ទះក្នុងពិធីបុណ្យចូលឆ្នាំចិន-វៀតណាមឆ្នាំនេះទេ



*ដោយ ខេមបូណ្ឌមីស*

នៅអំឡុងថ្ងៃបុណ្យចូលឆ្នាំប្រពៃណីចិន-វៀតណាម ទាំងប្រជាជនដែលមានដើមកំណើតចិន វៀតណាម និងអ្នកជាប់សែស្រឡាយចិន បានដើរទិញគ្រឿងរណ្តាប់សែន និង គ្រឿងលម្អតុបតែងផ្ទះសម្បែងដើម្បីសែនព្រេនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីចិន វៀតណាម ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២។

ក្រុមអាជីវករលក់គ្រឿងរណ្តាប់សែនចិនមួយចំនួននៅក្នុងផ្សារអូឬស្សី បានរៀបរាប់ថា ត្បិតឆ្នាំនេះ មានការរាតត្បាតជំងឺកូវីដ-១៩ ពិសេស មានវត្តមានវីរុសបំប្លែងថ្មី អូមីក្រុង ប៉ុន្តែការលក់ដូរនៅតែមានភាពល្អជាងឆ្នាំមុន ហើយតម្លៃទំនិញក៏ហាក់ឡើងថ្លៃជាងឆ្នាំមុនផងដែរ។

ទន្ទឹមនេះដែរ វិធានការទប់ស្កាត់ការឆ្លងកូវីដ១៩ ៣កុំ ៣ការពារ ក៏នៅតែកិច្ចការដែលត្រូវអនុវត្តប្រចាំថ្ងៃ ដើម្បីសុវត្ថិភាពពីការឆ្លងកូវីដ១៩៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី៣១ខែមករាឆ្នាំ២០២២។*

## តារាងប្រចាំសប្តាហ៍

### *រូបភាពទី១៖ ការប្រៀបធៀបការអនុវត្តចំណូលថវិកាថ្នាក់ជាតិ ក្នុងខែវិច្ឆិកា ឆ្នាំ២០២១*




រូបភាពទី១ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការប្រមូលចំណូល ក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណូលក្នុងប្រទេសសរុបមានចំនួនប្រហែល ១ ៤៥១ប៊ីលានរៀល ឬថយចុះ ៤៤% បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២០ ដែលមានចំនួនសរុបប្រមាណ ២ ៦១០ ប៊ីលានរៀល។

គិតត្រឹមរយៈពេល ១១ខែ នៃឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិ ប្រមូលចំណូលក្នុងប្រទេសសរុប បានសម្រេចបានតាមផែនការគ្រោងដែលមានចំនួនប្រហែល ១៧ ៧០០ ប៊ីលានរៀល ឬស្មើនឹង ៨៩% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២១ ខណៈដែល ការអនុវត្តក្នុងរយៈពេលដូចគ្នាឆ្នាំ២០២០ សម្រេចបានត្រឹមតែ ៨០% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០ប៉ុណ្ណោះ។ បើទោះបីជាវិបត្តិជំងឺកូវីដ-១៩ នៅតែបន្តជះឥទ្ធិពលលើសង្គម-សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២១នេះ ក៏ដោយ ក៏ការប្រមូលចំណូលក្នុងរយៈពេលពេល ១១ខែ នៃឆ្នាំ២០២១ បន្តរក្សាបាននូវ

និរន្តរភាព ហើយប្រហាក់ប្រហែលនឹងការការអនុវត្តនាឆ្នាំកន្លងមក៕ *ដោយ ឈន ហាំ*

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១*

### រូបភាពទី២៖ ការប្រៀបធៀបការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ខែវិច្ឆិកា ឆ្នាំ២០២១




រូបភាពទី២ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការអនុវត្តចំណាយថវិកា ក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណាយសរុបថ្នាក់ជាតិមានចំនួនប្រហែល ២ ២៦៨ប៊ីលានរៀល ឬកើនជិត ១% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០ ដែលមានចំនួនប្រហែល ២ ០២០ប៊ីលានរៀល។ កំណើននេះដោយសារ នូវតែបន្តចំណាយក្នុងការដោះស្រាយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។ ជាក់ស្តែង ក្នុងរយៈពេល ១១ខែ នៃឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយលើ អត្ថប្រយោជន៍សង្គម សម្រេចបានចំនួន ៣ ២៦៥ប៊ីលានរៀល ឬស្មើនឹង ១៤១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ដែលកើនឡើង ៦៨% ស្របពេលដែលចំណាយលើការទិញ ធ្លាក់ចុះជិត ៦% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០។

គិតត្រឹមរយៈពេល ១១ខែ នៃឆ្នាំ២០២១ ការអនុវត្តចំណាយសរុបថ្នាក់ជាតិ សម្រេចបានចំនួន២២ ៩៣៧ ប៊ីលានរៀល ឬស្មើនឹង៧៨% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១៕ *ដោយ ឈន ហាំ*

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ពាណិជ្ជកម្មរបស់ប្រទេសម៉ាឡេស៊ី នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១

ការនាំចេញរបស់ម៉ាឡេស៊ីមានតម្លៃ ១១២,២ប៊ីលានរីងហ្គីត នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ពោលគឺ បានកើនឡើង ៣២,៤% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ ការកើនឡើងនេះ ជារួម ត្រូវបានជំរុញជាចម្បងពីការនាំចេញក្នុងស្រុក (domestic exports) ក៏ដូចជាការនាំចេញឡើងវិញ (re-exports)។ ការនាំចេញក្នុងស្រុកមានចំនួន ៩៣,៧ប៊ីលានរីងហ្គីត ដែលស្មើនឹង ៨៣,៥% នៃការនាំចេញសរុប។ ដូចគ្នាដែរ ការនាំចេញឡើងវិញមានតម្លៃ១៨,៥ ពាន់លានរីងហ្គីត កើនឡើង ២៣,៩% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ រីឯ ការនាំចូលរបស់ម៉ាឡេស៊ី ក្នុងខែវិច្ឆិកា ឆ្នាំ ២០២១ មានចំនួនសរុប ៩៣,៣ប៊ីលានរីងហ្គីត ដែលមានកំណើន ៣៨% គួរឱ្យកត់សម្គាល់ ឬស្មើនឹង ២៥,៧ប៊ីលានរីងហ្គីត។

ដូច្នេះ ប្រទេសម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្មចំនួន ១៨,៩ប៊ីលានរីងហ្គីត ដែលមានកំណើន១០,៥% បើ

ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០៕

*ដោយ ធីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១១២,២ |
| ការនាំចេញ | ៩៣,៣ |
| តុល្យភាពពាណិជ្ជកម្ម | ១៨,៩ |

*ប្រភព៖ https://www.dosm.gov*

## ពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី សម្រាប់ខែធ្នូ ឆ្នាំ២០២១ (គិតជាប៊ីលានដុល្លារ)

ការនាំចេញទំនិញសរុបរបស់ប្រទេសឥណ្ឌូនេស៊ីមានចំនួន ២២,៣៨ប៊ីលានដុល្លារ នៅក្នុងខែធ្នូ ឆ្នាំ២០២១ ពោលគឺ កើនឡើង ៣៥,៣០% ធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុន ប៉ុន្តែបើធៀបទៅនឹងខែវិច្ឆិកា ឆ្នាំ២០២១ ការនាំចេញបានថយចុះ ២,០៤%។ ការនាំចេញផលិតផលមិនមែនប្រេង និងឧស្ម័ននៅក្នុងខែធ្នូ ឆ្នាំ២០២១ មានចំនួន២១,២៨ ពាន់លានដុល្លារ ថយចុះ ១,០៦% បើធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២១ ប៉ុន្តែបានកើនឡើង ៣៧,១៣% បើធៀបនឹងខែធ្នូ ឆ្នាំមុន។

ចំណែកឯ ការនាំចូលសរុបរបស់ឥណ្ឌូនេស៊ីមានទំហំ ២១,៣៦ប៊ីលានដុល្លារ នៅក្នុងខែធ្នូ ឆ្នាំ២០២១ បានកើនឡើង ៤៧,៩៣% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ប៉ុន្តែបើធៀបទៅនឹងខែវិច្ឆិកា ឆ្នាំ២០២១ ការនាំចេញបានកើនឡើងតែ១០,៥១%។ ការនាំចូលផលិតផលប្រេង និងឧស្ម័នមានតម្លៃ ៣,៣៨ប៊ីលានដុល្លារកើនឡើង ១១,៦៦% ធៀបទៅនឹងខែវិច្ឆិកា ឆ្នាំ២០២១ ខណៈការនាំចូលផលិតផលមិនមែនប្រេង និងឧស្ម័នមានតម្លៃ ១៧,៩៨ប៊ីលានដុល្លារ បានកើនឡើង ១០,២៩% ធៀបទៅនឹងខែវិច្ឆិកា ឆ្នាំ២០២១។

ជារួម ប្រទេសឥណ្ឌូនេស៊ីមានអតិរេកពាណិជ្ជកម្មចំនួន ១,០២ប៊ីលានដុល្លារ នៅក្នុងខែធ្នូ ឆ្នាំ២០២១៕

*ដោយ ធីម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ២២,៣៨ |
| ការនាំចេញ | ២១,៣៦ |
| តុល្យភាពពាណិជ្ជកម្ម | ១,០២ |

*ប្រភព៖ bps*

## អាមេរិកហាមឃាត់ការនាំចូលទំនិញពីក្រុមហ៊ុនម៉ាឡេស៊ី YTY Group ក្រោយសង្ស័យថាមានការរំលោភបំពានលើកម្មករ



*ដោយ ខេមបុណ្ណមីស*

ទីភ្នាក់ងារគយអាមេរិកបានធ្វើការហាមឃាត់ការនាំចូលស្រោមដៃវេជ្ជសាស្ត្ររបស់ម៉ាឡេស៊ី YTY Group ជុំវិញការបង្ខំលើកម្មករលើការអនុវត្តការងារ ដែលនេះផ្អែកលើព័ត៌មានដែលបង្ហាញពីការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំនៅក្នុងប្រតិបត្តិការផលិតកម្មរបស់ក្រុមហ៊ុន YTY Group។ នេះជាការហាមឃាត់លើកទី ៧ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។

ទីភ្នាក់ងារគយ និងការការពារព្រំដែនសហរដ្ឋអាមេរិកបានរកឃើញសូចនាករចំនួន ៧ ក្នុងចំណោមសូចនាករទាំង ១១នៃពលកម្មដោយបង្ខំ របស់អង្គការពលកម្មអន្តរជាតិ ក្នុងអំឡុងពេលស៊ើបអង្កេតរបស់ខ្លួនទៅលើ YTY Group រួមមាន៖ ការបំភិតបំភ័យ និងការគំរាម

កំហែង ការដាប់បំណុល ការរំលោភបំពានលើលក្ខខណ្ឌការងារ ការរស់នៅ និងការថែមម៉ោងធ្វើការច្រើនពេក។ ក្រុមហ៊ុនផលិតប្រេងដូងម៉ាឡេស៊ី ប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំក្នុងប្រតិបត្តិការរបស់ពួកគេ ហើយទំនិញរបស់ក្រុមហ៊ុនក៏ត្រូវរឹបអូសផងដែរ។ ក្រៅពីនេះ គយអាមេរិកប្រកាសថា នឹងធ្វើការចាប់ទំនិញដែលផលិតក្នុងប្រទេសម៉ាឡេស៊ី ដោយ YTY Group និងក្រុមហ៊ុនស្ថិតក្រោមក្រុមហ៊ុននេះមួយចំនួនទៀតនៅគ្រប់ច្រកចូលរបស់សហរដ្ឋអាមេរិក៕ *ដោយ ម៉ែន ខែមរៈ*
*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២។*

## ចក្ខុវិស័យកំណើនសេដ្ឋកិច្ចវៀតណាម កាន់តែភ្លឺស្វាងនៅឆ្នាំ ២០២២




*ប្រភព៖ Veitnam News, រូបភាព៖ Ngọc Bích*

ក្នុងឆ្នាំ២០២០ វៀតណាម គឺជាប្រទេសដ៏កម្រមួយ ដែលបានគ្រប់គ្រងរក្សាបានកំណើនសេដ្ឋកិច្ចវិជ្ជមាន ដោយ ផ.ស.ស បានកើនឡើង ២,៩១% ខណៈពេលដែលប្រទេសមួយចំនួនធំក្នុងពិភពលោក បានបង្ហាញកំណើនអវិជ្ជមាន។

ដោយឡែកនៅឆ្នាំ២០២១ ខណៈពេលដែលសេដ្ឋកិច្ចជុំវិញពិភពលោកកំពុងស្ថិតលើផ្លូវងើបឡើងវិញ ដោយសារការចាក់វ៉ាក់សាំងដែលត្រូវបានជំរុញនោះ សេដ្ឋកិច្ចវៀតណាម បែរជាទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺកូវីដបម្លែងថ្មីដែលតា។ ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ វៀតណាម មានកំណត់ត្រាផ.ស.ស ប្រចាំត្រីមាសអវិជ្ជ-មានជាលើកដំបូង។ សម្រាប់កំណើនផ.ស.ស ប្រចាំឆ្នាំ ២០២១ សេដ្ឋកិច្ច បានកើនឡើង២,៥៨% ដែលទាបជាងគោលដៅកំណើនប្រចាំឆ្នាំ ៦,៥% និងមានទំហំជិតពាក់កណ្តាលនៃអត្រាកំណើនផ.ស.ស សកល ៥.៩% ។ ក្នុងឆ្នាំ២០២២នេះ ជាថ្មីម្តងទៀត រដ្ឋាភិបាលវៀតណាម បានកំណត់គោលដៅអត្រាកំណើនសេដ្ឋកិច្ច ក្នុងអត្រាចន្លោះពី ៦% ទៅ ៦,៥%ដែលស្មើនឹងកម្រិតមធ្យមមុនការរីករាលដាលជំងឺកូវីដ-១៩។ ម្យ៉ាងវិញទៀត វាពិបាកនឹងនិយាយថា តើវាអាចនឹងសម្រេចបានតាមគោលដៅឬអត់ ដរាបណា ជំងឺរាតត្បាតមិនទាន់ស្ថិតក្រោមការគ្រប់គ្រងបាន។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញ និងស្ថាប័នជាច្រើន មានសុទិដ្ឋិនិយមចំពោះការស្ទុះងើបសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសនៅឆ្នាំនេះ។

ទន្ទឹមនឹងនេះ ធនាគារ Standard Chartered បានព្យាករណ៍ថា ការស្ទុះងើបឡើងវិញរបស់វៀតណាមនឹងកើនឡើងគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ ២០២២ ជាមួយនឹងកំណើន ៦,៧%។ នៅក្នុងរបាយការណ៍ "Vietnam at a Glance" នាពេលថ្មីៗនេះ ធនាគារ HSBC បានលើកឡើងថា បន្ទាប់ពីការធ្លាក់ចុះនៃកំណើនរយៈពេល ២ឆ្នាំ កំណើនសេដ្ឋកិច្ចរបស់ប្រទេសនេះ នឹងងើបស្ទុះឡើងវិញដើម្បីសម្រេចឈានដល់ ៦,៥% នៅឆ្នាំ២០២២។ ខណៈដែលពេលដែល ធនាគារពិភពលោក រំពឹងថា សេដ្ឋកិច្ចវៀតណាម នឹងស្ទុះងើបឡើងវិញជាមួយនឹង

កំណើនសេដ្ឋកិច្ច ត្រឹមតែ ៥,៥% ប៉ុណ្ណោះ ទោះបីមានការប្រុងប្រយ័ត្នជាងមុនក៏ដោយ។*ដោយ វត្ថា វង្សវឌ្ឍន:*
*ប្រភព៖ គេហទំព័រសារព័ត៌មាន Vietnam News ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២*

## សន្ទស្សន៍ផលិតកម្មកម្មន្តសាល MPI ត្រៀមនឹងកើនឡើង ៤-៥%



*ប្រភព៖ Bangkok Post*

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មលោក Suriya Jungrungreangkit រំពឹងថានឹងមានទស្សនវិស័យដ៏ភ្លឺស្វាង ក្នុងវិស័យឧស្សាហកម្មនៅឆ្នាំនេះ ដោយជឿជាក់ថាសន្ទស្សន៍ផលិតកម្មកម្មន្តសាល (MPI) របស់ប្រទេសថៃនឹងកើនឡើងពី ៤% ទៅ៥% ដែលជំរុញដោយការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក។ ជាពិសេស ការនាំចេញ និងវិធានការជំរុញនឹងបន្តផ្តល់អត្ថប្រយោជន៍ដល់ក្រុមហ៊ុនផលិត ហើយផ.ស.ស ក្នុងវិស័យឧស្សាហកម្មត្រូវបានរំពឹងថានឹងកើនឡើងពី ២,៥%ទៅ ៣,៥%។

លោក Thongchai Chawalitpichaet ប្រធានការិយាល័យសេដ្ឋកិច្ចឧស្សាហកម្ម (OIE) បានលើកឡើងថា MPI នៅក្នុងខែធ្នូឆ្នាំមុន បានកើនឡើង៦,៨៣% ធៀបនឹងឆ្នាំមុនដល់ ១០២,៥៩ពិន្ទុ ខណៈដែលកំណើនប្រចាំឆ្នាំ២០២១ MPI របស់ប្រទេសថៃ បានកើនឡើង ៥,៩៣% ជាមួយនឹងអត្រាប្រើប្រាស់សមត្ថភាពដែលបានកត់ត្រានៅ ៦៣,៧៣%។ ហើយឧស្សាហកម្មដែលរួមចំណែកដល់ការកើនឡើងនៃ MPI មានដូចជា ការផលិតគីមីឥន្ទនៈ រថយន្ត អេឡិចត្រូនិច និងបន្ទះសៀគ្វីវាយនភណ្ឌ និងកាត់ដេរ អាហារ ក៏ដូចជាសំបកកង់ និងកៅស៊ូ។

នៅខែធ្នូ ឧស្សាហកម្មរថយន្ត បានកើនឡើង ៩,១៥% ដោយសារតែតម្រូវការរថយន្តនៅក្នុងទីផ្សារពិភពលោកបានកើនឡើង ដែលជំរុញការនាំចេញរថយន្តពីប្រទេសថៃ។ ឧស្សាហកម្មប្រេង បានកើនឡើង ៧,៥៤% ដោយសារតម្រូវការប្រេងម៉ាស៊ូត និងប្រេងសាំងកើនឡើងបន្ទាប់ពីការបើកប្រទេសឡើងវិញ ក៏បានជំរុញឱ្យមានតម្រូវការប្រេងឥន្ទនៈផងដែរ។

ការផលិតស្ករ បានកើនឡើង ៣១,៥២% ដោយសារអាកាសធាតុសមស្របសម្រាប់ការដាំអំពៅ ដែលធ្វើឱ្យទិន្នផលដំណាំកាន់តែខ្ពស់ ខណៈដែរការផលិតគ្រឿងអេឡិចត្រូនិក និងបន្ទះសៀគ្វី បានកើនឡើង ១៤,២៤% ដោយសារតម្រូវការកើនឡើងសម្រាប់ផលិតផល ជាពិសេសគ្រឿងប្រើប្រាស់ក្នុងផ្ទះ និងរថយន្តអគ្គិសនីពីបរទេស។ *ដោយ វត្ថា វង្សវឌ្ឍន:*
*ប្រភព៖ គេហទំព័រសារព័ត៌មាន BangKok Post ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០២២*

## សេដ្ឋកិច្ចសកល

### លោកប្រធានាធិបតី ចូ បៃឌិន បានបញ្ចេញថវិកាជាង ១ប៊ីលានដុល្លារទៅតាមបណ្តារដ្ឋនានា ដើម្បីស្តារអណ្តូងប្រេង និងឧស្ម័នដែលត្រូវបោះបង់ចោលឡើងវិញ



*ប្រភព៖cnbc, ២០២១ រូបភាព៖ Mario Tama/ Getty Images*

លោកប្រធានាធិបតី Biden បានបញ្ជាក់ថា នឹងបញ្ជូនថវិការបស់រដ្ឋបាលចំនួន ១,១៥ប៊ីលានដុល្លារទៅកាន់បណ្តារដ្ឋនានា ដើម្បីស្តារអណ្តូងប្រេង និងឧស្ម័នជាច្រើនកន្លែង ដែលបញ្ចេញឧស្ម័នមេតាន ដែលជាឧស្ម័នផ្ទះកញ្ចក់ដែលបានផ្លាស់ប្តូរអាកាសធាតុដ៏ខ្លាំងក្លា។ សូមបញ្ជាក់ផងដែរ មេតានគឺជាសមាសធាតុសំខាន់នៃឧស្ម័នធម្មជាតិ ហើយមានចំនួន ១០% នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់សហរដ្ឋអាមេរិក រីឯ ឧស្សាហកម្មប្រេងនិងឧស្ម័នមាន ៣០% នៃការបំភាយឧស្ម័នមេតានរបស់ប្រទេស។ មេតានមានថាមពលខ្លាំងជាងកាបូន ៨៤ដង ហើយមិនមានរយៈពេលយូរនៅក្នុងបរិយាកាសមុនពេលវាបំបែក ដែលធ្វើឱ្យវាក្លាយជាគោលដៅសំខាន់សម្រាប់កាត់បន្ថយការឡើងកម្តៅផែនដីកាន់តែលឿន ខណៈពេល ដែលធ្វើការក្នុងពេលដំណាលគ្នាដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ផ្សេងទៀត។

មូលនិធិសម្រាប់ស្តារអណ្តូងប្រេង និងឧស្ម័នបានមកពីការប្រមូលចំណូលរបស់ហេដ្ឋារចនាសម្ព័ន្ធទ្វេភាគីរបស់ប្រធានាធិបតី Joe Biden ដែលបានបែងចែកទឹកប្រាក់សរុបចំនួន ៤,៧ប៊ីលានដុល្លារ ដើម្បីបង្កើតកម្មវិធីសហព័ន្ធថ្មីមួយដើម្បីដោះស្រាយអណ្តូងប្រេងជាច្រើនដែលត្រូវបានបោះបង់ចោលនៅទូទាំងប្រទេស។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃលោក Deb Haaland បានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍មួយថា ការផ្តល់មូលនិធិនេះអាចឱ្យរដ្ឋាភិបាល ប្រឈមមុខនឹងការបំពុលដល់ធម្មជាតិ និងអយុត្តិធម៌ទៅលើបរិស្ថានដែលអូសបន្លាយពេលយូរ និងមានផលរំខានដល់សហគមន៍។ ហេតុដូចនេះ រដ្ឋាភិបាលចាំបាច់ត្រូវធ្វើសកម្មភាពជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហាអណ្តូងដែលត្រូវបានទុកចោលជាច្រើនកន្លែងនៅទូទាំងប្រទេស ហើយក៏មិនត្រូវទុកសហគមន៍ចោលនោះដែរ ដែលនេះជារឿងល្អសម្រាប់អាកាសធាតុ សម្រាប់សុខភាពសហគមន៍ និងសម្រាប់កម្មករអាមេរិក។ ប្រាក់មូលនិធិនេះនឹងទៅដល់រដ្ឋចំនួន ២៦ ដែលបានដាក់ការជូនដំណឹងអំពីចេតនាទៅកាន់នាយកដ្ឋានមហាផ្ទៃកាលពីឆ្នាំមុន រួមទាំងច្រើនជាង ១០០លានដុល្លារសម្រាប់រដ្ឋ Pennsylvania និង Texas ។ មនុស្សប្រហែល ៩លាននាក់រស់នៅក្នុងចម្ងាយមួយម៉ាយពីអណ្តូងប្រេង និងឧស្ម័នដែលគេបោះបង់ចោល ដែលខ្លះបញ្ចេញឧស្ម័នដែលបង្កគ្រោះថ្នាក់ដែលប៉ះពាល់ដល់សហគមន៍ដែលមានចំណូលទាបនៅក្នុងសហរដ្ឋអាមេរិក។

លោក Mahyar Sorour អនុប្រធាននីតិប្បញ្ញត្តិនៃ Sierra Club បានមានប្រសាសន៍ថា៖ ការដោះស្រាយអណ្តូងដែល មានស្រាប់ទាំងនេះគឺជាជំហានដំបូងដ៏សំខាន់ ក៏ប៉ុន្តែ លុះត្រាតែ វាត្រូវបានផ្គូរផ្គងជាមួយនឹងកំណែទម្រង់ចំណងដែលទាមទារឱ្យក្រុមហ៊ុនប្រេង និងឧស្ម័ន រ៉ាប់រងការចំណាយទាំងនេះជាមុនសិន។ គួរបញ្ជាក់ថា ឧស្សាហកម្មនេះ នឹងបន្តបន្សល់ទុកនូវអណ្តូងដែលបំពុលនៅលើដីសាធារណៈ ហើយរំពឹងថាអ្នកបង់ពន្ធនឹងរ៉ាប់រងលើថ្លៃដើមសម្អាតអណ្តូងនោះ។ លោក Bethany Williams អ្នកនាំពាក្យរបស់វិទ្យាស្ថានប្រេងអាមេរិក ដែលជាក្រុមពាណិជ្ជកម្មធំបំផុតនៃឧស្សាហកម្មប្រេង និងឧស្ម័នបានគាំទ្រលើកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋបាល ក្នុងការដោះស្រាយអណ្តូងដែលត្រូវបានទុកចោលនោះ។

កាលពីឆ្នាំមុន API បានចេញផ្សាយស្តង់ដារឧស្សាហកម្មថ្មី ដើម្បីដោះស្រាយការបិទ និងការជួសជុលអណ្តូងដែលមានកិច្ចព្រមព្រៀង Global Methane Pledge ដែលជាកិច្ចព្រមព្រៀងមួយដើម្បីកាត់បន្ថយការបំភាយឧស្ម័នមេតាន ចំនួន ៣០% នៅចុងទសវត្សរ៍នេះ។

ប្រទេសជាង ១០០ បានចូលរួមកិច្ចព្រមព្រៀងនេះ រួមទាំង ១៥ប្រទេស ដែលបញ្ចេញឧស្ម័នមេតាន ៣០% លើពិភពលោក។

កិច្ចព្រមព្រៀងនេះបានខិតខំប្រឹងប្រែង ដើម្បីតម្រូវឱ្យប្រតិបត្តិករ យកចិត្តទុកដាក់លើបំពង់បង្ហូរប្រេងដើម្បីកាត់បន្ថយការលេចធ្លាយឧស្ម័នមេតាន និងធ្វើការស្រាវជ្រាវដើម្បីទប់ស្កាត់ការបញ្ចេញឧស្ម័នមេតាន ពីប្រព័ន្ធសាច់គោ និងទឹកដោះគោ និងបង្កើតក្រុមការងារអន្តរកម្មថ្មីមួយ ដើម្បីសម្របសម្រួលការវាស់វែង តាមដាន និងរាយការណ៍ពីការបំភាយឧស្ម័នផ្ទះកញ្ចក់៕

*ដោយ សេន ចន្ទី*

*ប្រភព៖cncb.com, ចេញផ្សាយថ្ងៃទី៣១ខែមករា ឆ្នាំ២០២២*

## សហព័ន្ធការងារ និងសភានៃអង្គការឧស្សាហកម្មអាមេរិក (AFL-CIO) បានគាំទ្រយ៉ាងខ្លាំងចំពោះប្រព័ន្ធទូទាត់ អន្តរធនាគារ (CHIPs) ដែលជាកន្លែងទូទាត់ប្រាក់ចម្បងនៅUSA សម្រាប់ ប្រតិបត្តិការធនាគារធំរបស់សភាអាមេរិកក្នុងការការប្រកួតប្រជែងក្នុងប្រទេសចិន



*ប្រភព៖ Reuters, ២០២២ រូបភាព៖ Brian Snyder*

អង្គការការងារដ៏ធំបំផុតរបស់សហរដ្ឋអាមេរិកបានបញ្ជាក់ពីការគាំទ្រយ៉ាងខ្លាំងរបស់ខ្លួនចំពោះសេចក្តីព្រាងច្បាប់របស់សភាតំណាងរាស្ត្រសហរដ្ឋអាមេរិកដែលបានបង្កើតឡើងដើម្បីកែលម្អការប្រកួតប្រជែងជាមួយប្រទេសចិន តាមរយៈការជំរុញលើការផលិតគ្រឿងអេឡិចត្រូនិច (semi-conductor) របស់សហរដ្ឋអាមេរិក និងកំណែទម្រង់បទប្បញ្ញត្តិពាណិជ្ជកម្មសំខាន់ៗ។

សហព័ន្ធពាណិជ្ជកម្ម AFL-CIO ដែលតំណាងឱ្យកម្មករ ១២,៥លាននាក់ បានធ្វើលិខិតមួយទៅកាន់សមាជិកសភា ដោយបញ្ជាក់ថា ថវិកា ៥២ប៊ីលានដុល្លារនៃការទូទាត់ CHIPS គឺមានសារៈសំខាន់ ក្នុងការដោះស្រាយកង្វះការទូទាត់តាម CHIPs បច្ចុប្បន្នដែលបន្តជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ផលិតកម្មក្នុងវិស័យរថយន្ត និងកន្លែងផ្សេងទៀត។

សភាអាមេរិកគ្រោងនឹងលើកយកលិខិតមួយនេះដើម្បីពិចារណាលើវិសោធនកម្ម ដែលត្រូវបានស្នើឡើងដោយជាង ៥០០លិខិត លើការទូទាត់ រួមទាំង អ្នកតំណាង Alexandria Ocasio-Cortez និង Cori Bush ដែលបានរាំងក្រុមហ៊ុនផលិត semiconductor ដែលទទួលបានប្រាក់ឧបត្ថម្ភពី រដ្ឋាភិបាលពីការបង់ភាគលាភ ឬការទិញភាគហ៊ុនក្រុមហ៊ុនឡើងវិញ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម Gina Raimondo នឹងព្យាយាម ផ្តល់ដំណឹងនេះទៅកាន់សមាជិកសភាគណបក្សប្រជាធិបតេយ្យអំពីសារៈសំខាន់នៃច្បាប់នេះ ព្រោះសហជីពបានបញ្ជាក់ថាការទូទាត់នេះនឹងផ្តល់នូវការកែលម្អដ៏សំខាន់ ក៏ដូចជាលើសមត្ថភាពប្រកួតប្រជែងជាសកលរបស់អាមេរិក ព្រមទាំង ការគាំទ្រកម្មករដែលបាត់បង់ការងារធ្វើពាណិជ្ជកម្ម ការការពារនិងការពង្រីកឧបករណ៍ដើម្បីប្រយុទ្ធប្រឆាំងនឹងពាណិជ្ជកម្មអយុត្តិធម៌ពីបរទេស។

ទន្ទឹមនឹងនេះ សភាពាណិជ្ជកម្មសហរដ្ឋអាមេរិកបានបញ្ជាក់ពីភាពរីករាយដែលសភាកំពុងចាប់ផ្តើមដំណើរការពិចារណាលើកំណែទម្រង់ច្បាប់មួយនេះ។ សកម្មភាពរបស់សភា គឺជាជំហានសំខាន់មួយក្នុងការធ្វើកំណែ

ទម្រង់នេះ ដែលអាចចុះហត្ថលេខាជាច្បាប់ថ្មី។ សភានឹងបោះឆ្នោតលើសេចក្តីព្រាងច្បាប់ដែលមាន ២ ៩០០ ទំព័រដែលហៅថាច្បាប់ "ការប្រកួតប្រជែងអាមេរិក"។ នៅក្នុងសេចក្តីព្រាងនេះ បានផ្តល់សិទ្ធិ ៤៥ប៊ីលានដុល្លារ ដើម្បីគាំទ្រដល់ភាពធន់នៃខ្សែសង្វាក់ផ្គត់ផ្គង់ និងការផលិតទំនិញសំខាន់ៗ និងឧបករណ៍ឧស្សាហកម្ម។ រដ្ឋបាលរបស់ប្រធានាធិបតី Joe Biden កំពុងជំរុញឱ្យសភាអនុម័តការផ្តល់មូលនិធិសម្រាប់ឧបត្ថម្ភធនដល់ការទូទាត់ CHIPs នៅក្នុងសហរដ្ឋអាមេរិក ដោយសារតែកង្វះខាតនៃសមាសភាគដែលប្រើប្រាស់ក្នុងយានយន្ត និងកុំព្យូទ័របានធ្វើឱ្យមានការរាំងស្ទះ ដល់ខ្សែសង្វាក់ផ្គត់ផ្គង់។

ព្រឹទ្ធសភាបានអនុម័តច្បាប់ស្តីពីការបង្កើតថ្មី និងការប្រកួតប្រជែងរបស់សហរដ្ឋអាមេរិកកាលពីឆ្នាំមុន ដែលរួមបញ្ចូល ៥២ប៊ីលានដុល្លារ សម្រាប់ការទូទាត់ និង ១៩០ប៊ីលានដុល្លារដើម្បីពង្រឹងបច្ចេកវិទ្យា និងការស្រាវជ្រាវរបស់សហរដ្ឋអាមេរិក ដើម្បីប្រកួតប្រជែងជាមួយប្រទេសចិន។ សេចក្តីព្រាងច្បាប់របស់សភា មានភាពខុសគ្នាខ្លះជាមួយកំណែទម្រង់របស់ព្រឹទ្ធសភា។

ប្រសិនបើត្រូវបានអនុម័ត ថ្នាក់ដឹកនាំនៃសភាទាំងពីរនឹងចរចាដើម្បីដោះស្រាយការខ្វែងគំនិត។ AFL-CIO បានគាំទ្រដំណើរការត្រួតពិនិត្យថ្មី ដើម្បីការពារខ្សែសង្វាក់ផ្គត់ផ្គង់ ដោយការពិនិត្យមើលការវិនិយោគក្រៅប្រទេស និងការពារប្រឆាំងនឹងការទម្លាក់សមត្ថភាពសំខាន់ៗដល់សត្រូវ ដូចជា ចិន និងរុស្ស៊ី។ *ដោយ សេន ចន្ទី*

*ប្រភព៖reuters.com,ចេញផ្សាយថ្ងៃទី០១ខែកុម្ភៈ ឆ្នាំ២០២២*

## ទីផ្សារភាគហ៊ុនអាស៊ីកើនឡើង ខណៈតម្លៃប្រេងឆៅនៅអង់គ្លេសកើនដល់ ៩១ដុល្លារអាមេរិក



*ដោយ ខេមបូណ្ឌមីស*

ផ្សារភាគហ៊ុននៅអាស៊ីនៅថ្ងៃចន្ទដើមសប្តាហ៍នេះ មានការកើនឡើងខ្ពស់ជាងមុន ស្របពេលដែលទីផ្សារភាគហ៊ុននៅ Wall Street នៅមានសភាពទ្រឹង។ ការឈប់សម្រាកចូលបុណ្យចូលឆ្នាំចិន គឺបានធ្វើឱ្យមានឥទ្ធិពលតិចតួច ដោយសន្ទស្សន៍ភាគហ៊ុននៅអាស៊ីប៉ាស៊ីហ្វិកក្រៅពីប្រទេសជប៉ុនបានកើនឡើង ០,៦% នៅក្នុងកម្រិតជួញដូរយឺត។

បញ្ហាវិបត្តិនៅប្រទេសអ៊ុយក្រែន ក៏នៅតែមានឥទ្ធិពលចំពោះទីផ្សារ ដោយគេកំពុងបារម្ភថា ប្រទេសរុស្ស៊ីអាចនឹងលុកលុយចូលអ៊ុយក្រែន ដែលអាចនឹងធ្វើឱ្យមានការកាត់បន្ថយការផ្គត់ផ្គង់ឧស្ម័នទៅកាន់ទីផ្សារប្រទេសអឺរ៉ុបខាងលិច។

ក្រឡេកទៅមើលតម្លៃប្រេងឆៅវិញ ឃើញថា តម្លៃប្រេងបានកើនឡើងដល់កម្រិតខ្ពស់បំផុត ហើយការកើនឡើងនេះ គឺមានការកើនឡើង ៦សប្តាហ៍ជាប់ៗគ្នា នេះ ដោយសារតែមានភាពតានតឹងកាន់តែខ្លាំងទៅលើភូមិសាស្ត្រនយោបាយ ដែលបង្កឱ្យមានក្តីបារម្ភពីការផ្គត់ផ្គង់ថាមពល។ ដោយឡែក តម្លៃប្រេងឆៅនៅអង់គ្លេស បានកើនឡើង ១,១៨ដុល្លារបន្ថែមទៀត នៅសប្តាហ៍នេះ ដោយប្រេងឆៅមួយបារ៉ែលមានតម្លៃដល់ទៅ ៩១,២១ដុល្លារ ខណៈនៅទីផ្សារអាមេរិកវិញ ក៏កើនឡើង ១,១៥ដុល្លារ

ផងដែរ ធ្វើឱ្យតម្លៃប្រេងកើនដល់ទៅជិត ៨៨ដុល្លារក្នុងមួយបារ៉ែល៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០១ខែកុម្ភៈ ឆ្នាំ២០២២។*

## សហភាពអឺរ៉ុបចេញមុខការពារប្រទេសលីទុយអានី លើបញ្ហាជម្លោះការទូតពាណិជ្ជកម្ម ដោយបានប្ដឹងចិនទៅ WTO



*ដោយ ខេមបូណូមីស*

នៅទីបំផុត សហភាពអឺរ៉ុប បានចេញមុខការពារប្រទេសលីទុយអានី ជុំវិញបញ្ហាជម្លោះការទូតពាណិជ្ជកម្មជាមួយប្រទេសចិន។ សហភាពអឺរ៉ុបក៏បាននាំយកសំណុំរឿង ដែលចិនបានធ្វើការបិទខ្ទប់ការនាំចូលផលិតផលរបស់ប្រទេសលីទុយអានី ទៅកាន់អង្គការពាណិជ្ជកម្មពិភពលោក ដោយអឺរ៉ុបបានចោទប្ដឹងរដ្ឋាភិបាលប៉េកាំងថា លើការធ្វើឱ្យខូចដល់ទីផ្សាររួមរបស់តំបន់អឺរ៉ុបទាំង ២៧ប្រទេស។

នៅចំពោះមុខ អង្គការពាណិជ្ជកម្មពិភពលោក ដែលមាន ស្នងការពាណិជ្ជកម្មសហភាពអឺរ៉ុប បានស្នើឱ្យចិនមានការគោរពដល់ប្រទេសជាដៃគូពាណិជ្ជកម្មនឹងគ្នា ជាពិសេស ឈប់ដាក់សម្ពាធពាណិជ្ជកម្ម ក៏ដូចជា ការបិទខ្ទប់ការនាំចូលទំនិញ ក្រោមហេតុផលនយោបាយផងដែរ។ ចិនបានរាំងខ្ទប់ការនាំចូលទំនិញពីប្រទេសលីទុយអានី ចាប់តាំងពីពេលដែលប្រទេសនេះបានអនុញ្ញាតឱ្យកោះតៃវ៉ាន់មានការិយាល័យតំណាងនៅក្នុងប្រទេស រួចមក ក្រោមឈ្មោះថា «តៃវ៉ាន់» ជំនួសឱ្យការប្រើឈ្មោះថា «កោះតៃវ៉ាន់នៃប្រទេសចិន»។ ជាងនេះទៅទៀត ប្រទេសចិន បានកំពុងដាក់សម្ពាធលើក្រុមហ៊ុនអន្តរជាតិ ឱ្យបោះបង់ចោលការប្រើប្រាស់ផលិតផលពីប្រទេសលីទុយអានី ក្នុងការផលិតរបស់ពួកគេដើម្បីនាំចេញទំនិញមកទីផ្សារចិន។ បើមិនដូច្នោះទេ ពួកគេអាចប្រឈមនឹងការរឹតបន្តឹងការនាំចូល។

អឺរ៉ុបបានចាត់ទុក ចំណាត់ការរបស់ប៉េកាំងលើករណីនេះ ជាការគំរាមកំហែងដល់ទីផ្សារតែមួយរបស់សហភាពអឺរ៉ុប ដូច្នេះ វាប៉ះពាល់ដល់ពាណិជ្ជកម្ម ប៉ះពាល់ខ្សែសង្វាក់ផ្គត់ផ្គង់ ហើយនឹងមានឥទ្ធិពលអវិជ្ជមានលើឧស្សាហកម្មរបស់សហភាពអឺរ៉ុបទាំងមូលផង៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២។*

## សេដ្ឋកិច្ចតៃវ៉ាន់ឆ្នាំ២០២១ កើនឡើងលឿនបំផុត




*ដោយ ខេមបូណូមីស*

បើទោះបីជាស្ថិតក្រោមសម្ពាធកាន់តែខ្លាំងពីសំណាក់រដ្ឋាភិបាលប៉េកាំង ប៉ុន្តែកោះតៃវ៉ាន់ នៅតែរក្សាជំហរឹងមាំរបស់ខ្លួនទាំងនៅក្នុងផ្នែកនយោបាយ យោធា និងសេដ្ឋកិច្ច។ ជាក់ស្ដែង នៅឆ្នាំ២០២១កន្លងទៅនេះ សេដ្ឋកិច្ចកោះតៃវ៉ាន់ សម្រេចបានកំណើនជាង ៦% ធៀបនឹងឆ្នាំ២០២០ ដែលមានកំណើនត្រឹមតែជាង ៣% ប៉ុណ្ណោះ។ នេះគឺជាអត្រាកំណើនលឿនបំផុតមិនធ្លាប់មាន គិតក្នុងរយៈពេលជាង១ទសវត្សរ៍កន្លងមកនេះ

ចាប់តាំងពីឆ្នាំ២០១០មក។ កំណើននេះ ត្រូវបានរុញយ៉ាងខ្លាំងក្លាពីការនាំចេញផលិតផលបច្ចេកវិទ្យា កំណើនការងារ ស្របពេលដែលទំនុកចិត្តអ្នកប្រើប្រាស់ក៏កំពុងងើបឡើងវិញផងដែរ។

សេដ្ឋកិច្ចកោះតៃវ៉ាន់ មានការលូតលាស់យ៉ាងល្អប្រសើរ ធៀបនឹងដៃគូក្នុងតំបន់ ពិសេសការនាំចេញ។ ការនាំចេញរបស់កោះតៃវ៉ាន់ កើនឡើងជិត៣០% នៅក្នុងឆ្នាំ២០២១នេះ ដែលជាអត្រាកំណើនខ្ពស់មួយ ហើយសេដ្ឋកិច្ចដែនកោះមួយនេះ ក៏បន្តទទួលបានប្រយោជន៍កាន់តែច្រើន ពីតម្រូវការកើនឡើងខ្ពស់សម្រាប់ការនាំចេញផលិតផលបច្ចេកវិទ្យាកម្រិតខ្ពស់ និងបន្ទះឈីប។ ទោះជាយ៉ាងណា នៅឆ្នាំ២០២២នេះ ការនាំចេញរបស់កោះតៃវ៉ាន់ ត្រូវបានស្ថាប័នស្រាវជ្រាវសេដ្ឋកិច្ច Capital Economics អះអាងថា ទំនងជានឹងមិនអាចកើនឡើងដូចឆ្នាំកន្លងទៅនោះទេ ដោយសារតែអត្រាអតិផរណាខ្ពស់ និងការគាំទ្រសារពើពន្ធធ្លាក់ចុះ ដែលនឹងបង្កឱ្យប៉ះពាល់ដល់ការចំណាយ។ ហានិភ័យមួយទៀតនោះ គឺសេដ្ឋកិច្ចចិនមានកំណើនយឺត ដោយសារតែចិនក៏ជាដៃគូពាណិជ្ជកម្មធំមួយរបស់កោះតៃវ៉ាន់ផងដែរ៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូឌាមីស ចេញផ្សាយថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២។*

## **ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់**

ថ្ងៃចន្ទ ទី០៧ ខែកុម្ភៈ ឆ្នាំ២០២២

- សេដ្ឋកិច្ចប្រទេសឥណ្ឌូនេស៊ី បានកើនឡើងនៅក្នុងត្រីមាសទី៣ នៃឆ្នាំ២០២១
- ទុនបម្រុងរូបិយប័ណ្ណបរទេស នៅក្នុងប្រទេសរុស្ស៊ីបានកើនឡើង ក្នុងខែធ្នូ ឆ្នាំ២០២១

ថ្ងៃអង្គារ ទី០៨ ខែកុម្ភៈ ឆ្នាំ២០២២

- ឱនភាពពាណិជ្ជកម្មប្រទេសបារាំង ក្នុងខែវិច្ឆិកា ឆ្នាំ២០២១
- អតិរេកពាណិជ្ជកម្មប្រទេសកាណាដាបានកើនឡើង ក្នុងខែវិច្ឆិកា ឆ្នាំ២០២១

ថ្ងៃពុធ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មអាឡឺម៉ង់បានធ្លាក់ចុះ ក្នុងខែវិច្ឆិកា ឆ្នាំ២០២១
- អត្រាអតិផរណាប្រចាំឆ្នាំ ក្នុងប្រទេសប្រេស៊ីលបានថយចុះ ក្នុងខែធ្នូ ឆ្នាំ២០២១

ថ្ងៃព្រហស្បតិ៍ ទី១០ ខែកុម្ភៈ ឆ្នាំ២០២២

- កំណើនអត្រានីកម្មភាព បានកែសម្រួលតាមរដូវកាលនៅក្នុងប្រទេសកូរ៉េខាងត្បូង ឡើងដល់ ៣,៨% ក្នុងខែធ្នូ ឆ្នាំ២០២១
- តម្លៃនៃប្រាក់កម្ចីនៅក្នុងប្រទេសចិនបានកើនឡើង ១១,៦០% នៅក្នុងខែធ្នូ ឆ្នាំ២០២១ ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន

ថ្ងៃសុក្រ ទី១១ ខែកុម្ភៈ ឆ្នាំ២០២២

- ចក្រភពអង់គ្លេសបានប្រកាសអតិរេកពាណិជ្ជកម្ម GBP ០,៦៣ប៊ីលាន លើសពី GBP ០,១៥ ប៊ីលានកាលពីខែមុន
- អតិរេកពាណិជ្ជកម្មរបស់រុស្ស៊ីបានកើនឡើងដល់ ២១,០៦ប៊ីលានដុល្លារក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ពី ៧,៣៩ប៊ីលានដុល្លារក្នុងខែដែលត្រូវគ្នានៃឆ្នាំមុន៕